# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា

CAMBODIA WATCHDOG COUNCIL

## សេចក្តីថ្លែងការណ៍

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សម្តែងការព្រួយបារម្ភចំពោះការរីករាលដាលជំងឺកូវីដ១៩ ប្រភេទថ្មី«អូមី-ក្រុង» ដែលអាចឆ្លងចូលទៅក្នុងពន្ធនាគារព្រៃស និងពន្ធនាគារនានានៅទូទាំងប្រទេស ដោយមិនបានប្រតិបត្តិត្រឹមត្រូវ តាមវិធានសុខាភិបាល នៃក្រសួងសុខាភិបាល។ ដោយហេតុថា ក្នុងបន្ទប់ពន្ធនាគារនីមួយៗ មានផ្ទុកមនុស្សច្រើនជាង ២០នាក់ ដែលជាកត្តាងាយរងគ្រោះបំផុត បើសិនមេរោគអូមីក្រុង ឆ្លងចូលក្នុងពន្ធនាគារ ជាយថាហេតុណាមួយ។

ជាងនេះទៀត យើងខ្ញុំកត់សម្គាល់ឃើញថា សកម្មជនសង្គម សកម្មជននយោបាយ និងអ្នកទោសមនសិការភាគច្រើន ត្រូវបានឃុំខ្លួនលើសនីតិវិធីកំណត់ (លើស ១៨ខែ) ដោយគ្មានការជំនុំជម្រះត្រឹមត្រូវ និងមិនបានទទួលយុត្តិធម៌។ ករណីឃុំខ្លួនលើសនីតិវិធីនេះ គួរតែត្រូវបានពិនិត្យដោះស្រាយតាមយន្តការច្បាប់ ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះពិតប្រាកដ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមអំពាវនាវដល់ក្រសួងសុខាភិបាល និងមន្ត្រីពន្ធនាគារ យកចិត្តទុកដាក់ផ្តល់សេវាសុខភាព តាមវិធានសុខាភិបាល ជូនដល់បងប្អូនប្រជាពលរដ្ឋដែលកំពុងជាប់ឃុំនៅពន្ធនាគារ ឲ្យមានប្រសិទ្ធភាពខ្ពស់ ជាការបង្ការការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ប្រភេទអូមីក្រុងថ្មី។

សូមអំពាវនាវដល់តុលាការ និងរាជរដ្ឋាភិបាល ទម្លាក់ចោលបទចោទប្រកាន់នានា ហើយត្រូវផ្តល់យុត្តិធម៌ និងដោះលែងក្រុមសកម្មជនសង្គម សកម្មជននយោបាយ និងអ្នកទោសមនសិការ ឲ្យមានសេរីភាពឡើងវិញ ស្របតាមខ្លឹមសាររដ្ឋធម្មនុញ្ញកម្ពុជា តាមគោលការណ៍ច្បាប់គតិយុត្តិ និងសេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

ថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

*រាជធានីភ្នំពេញ* ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២

**តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**រ៉ុង ឈុន**

**ប្រធានសហភាពសហជីពកម្ពុជា**